**BMI0151**

**សម្ភាសន៍ជាមួយឈ្មោះ ម៉ាក់ ស៊ីលឿត ភេទស្រី អាយុ៥២ឆ្នាំ**

**មុខងាររដ្ឋនាន់ខ្មែរក្រហម "ប្រជាជនធ្វើការនៅកងចល័ត"**

**ស្រុកកំណើតនៅភូមិកណ្តាល ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ**

**ខេត្តបន្ទាយមានជ័យ**

**រស់នៅភូមិកណ្តាល ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ**

**ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ ឆាយ ឈុនលី**

**០០:៤៨:២១**

**២៣ទំព័រ**

ឈុនលី ៖ អ៊ីចឹងថ្ងៃនេះទី១៦ ខែ៦ ឆ្នាំ២០១១ ។ មីងខ្ញុំសុំស្គាល់ឈ្មោះមីង មីងឈ្មោះអី?

ស៊ីលឿត ៖ ឈ្មោះ ម៉ាក់ ស៊ីលឿត ។

ឈុនលី ៖ ស៊ីលឿត?

ស៊ីលឿត ៖ ចាំ!

ឈុនលី ៖ អាយុប៉ុន្មានហើយមីង?

ស៊ីលឿត ៖ ៥២ ។

ឈុនលី ៖ ៥២ ភេទស្រី នៅភូមិ?

ស៊ីលឿត ៖ កណ្តាល ។

ឈុនលី ៖ កណ្តាល ឃុំព្រះនេត្រព្រះ?

ស៊ីលឿត ៖ ចាំ!

ឈុនលី ៖ មីងមានបងប្អូនប៉ុន្មាននាក់?

ស៊ីលឿត ៖ អត់មាន មានតែម្នាក់ឯង ។

ឈុនលី ៖ កូនទោល?

ស៊ីលឿត ៖ ចាំ!ដូចថាម្តាយតែមួយ ឪផ្សេងណាស ខ្ញុំម្នាក់ឯង ។

ឈុនលី ៖ ចុះឪពុកមីងមានប្រពន្ធមួយទៀត?

ស៊ីលឿត ៖ អត់ទេ ម្តាយ! ដូចថាប្តីដើមគាត់មានកូនបួនផ្សេងណាស ដល់ខ្ញុំកូនក្រោយម្នាក់ឯង ។

ឈុនលី ៖ ចឹងមីងកូនប្តីទី២?

ស៊ីលឿត ៖ ចា៎!

ឈុនលី ៖ ម្តាយមីងឈ្មោះអី?

ស៊ីលឿត ៖ ឈ្មោះ ជួប មូល ខូចហើយ ។

ឈុនលី ៖ ជួប មូល?

ស៊ីលឿត ៖ ចា៎!

ឈុនលី ៖ ឪពុក?

ស៊ីលឿត ៖ ម៉ាក់ លឿន ។

ឈុនលី ៖ មីងរៀនបានថ្នាក់ទីប៉ុន្មាន?

ស៊ីលឿត ៖ ថ្នាក់ទី៩ ។

ឈុនលី ៖ នៅទីនេះសំបូរអ្នករៀនបានថ្នាក់ទី៩ ។

ស៊ីលឿត ៖ ទី៩ពីដើមមិនចេះអីទេ!

ឈុនលី ៖ ថ្នាក់ទី៩ប្រហែលថ្នាកទី៤ ទី៥?

ស៊ីលឿត ៖ ចា៎!

ឈុនលី ៖ មីងនៅភូមិនេះខ្មែរក្រហមចូលឆ្នាំណា?

ស៊ីលឿត ៖ ចូលសន្តិភាពហ្អី?

ឈុនលី ៖ ចូលមកកាន់កាប់ណាស!

ស៊ីលឿត ៖ ៧៥ ។

ឈុនលី ៖ ៧៥ហ្អីចូលមកដល់ភូមិហ្នឹង?

ស៊ីលឿត ៖ ៧៥ ៧៩យើងមិនអ្នកស្រុកចូលវិញ ។

ឈុនលី ៖ ចុះពេលខ្មែរក្រហមចូលមកមីងធ្វើអី?

ស៊ីលឿត ៖ ធ្វើនារី!

ឈុនលី ៖ ចុះមុនខ្មែរក្រហមមីងធ្វើអី?

ស៊ីលឿត ៖ មុនខ្មែរក្រហមនៅតែរៀន ។

ឈុនលី ៖ នៅរៀន?

ស៊ីលឿត ៖ ចា៎!

ឈុនលី ៖ ហើយឪពុកម្តាយមីងធ្វើអី?

ស៊ីលឿត ៖ ធ្វើស្រែ

ឈុនលី ៖ ដល់ពេលខ្មែរក្រហមចូលមកឈប់រៀន?

ស៊ីលឿត ៖ ចាំ! ឈប់ពេលខ្មែរក្រហមចូល ។

ឈុនលី ៖ ដំបូងពេលខ្មែរក្រហមចូលមកសភាពការណ៍យ៉ាងម៉េចទៅ?

ស៊ីលឿត ៖ ឈប់រៀនទៅគេជម្លៀស ខ្មែរក្រហមជម្លៀសទៅនៅភ្នំកូនដំរីនេះ ជម្លៀសពីភូមិនេះណាស ។

ឈុនលី ៖ ជម្លៀសទៅប៉ុន្មាននាក់ទៅ?

ស៊ីលឿត ៖ ទៅទាំងអស់ម៉ាភូមិនេះទាំងអស់គ្នាប្រហែលម៉ាអាទិត្យទេដឹង ។

ឈុនលី ៖ ទៅនៅភ្នំកូនដំរី?

ស៊ីលឿត ៖ ចាំ!ភ្នំកូនដំរីអីត្បូង ។

ឈុនលី ៖ អាហ្នឹងភូមិហ្នឹ?

ស៊ីលឿត ៖ សព្វថ្ងៃបង្កើតភូមិហើយ ផ្ទះបួនដប់ ។ កាលមុនអត់មានភូមិទេមានតែភ្នំមួយ ភ្នំកូនដំរី ។

ឈុនលី ៖ ហើយទៅហ្នឹងធ្វើអីគេទៅ?

ស៊ីលឿត ៖ ទៅនោះអត់ទាន់បានធ្វើអីទេ ភ្នំកូនដំរី ប្រហែលមួយអាទិត្យក៏ទៅនៅស្រែះទៀត ភូមិស្រែះយើងនេះ ។

ឈុនលី ៖ ទៅធ្វើអីគេនៅស្រែះហ្នឹង?

ស៊ីលឿត ៖ នៅស្រែះក៏ទៅនៅធ្វើខ្ទមធម្មតាទៅក៏ពួកខ្មែរក្រហមក្តាប់ កាលនោះខ្មែរក្រហមចូលក្តាប់ហើយណាស រើចោលខ្លះទៅ ។ ដល់រួចពីនោះមកចេញពីស្រែះទៅនៅភូមិប៉ោយព្រីង ។ ទៅនៅប៉ោយព្រីងប្រហែលម៉ាខែគេជម្លៀសទៅនៅត្រពាំងវែង ។

ឈុនលី ៖ ត្រពាំងវែង?

ស៊ីលឿត ៖ ត្រពាំងវែងដែលយើងនៅខាងត្បូងជើងភ្នំ ។

ឈុនលី ៖ ទៅនៅប៉ោយព្រីងហ្នឹងធ្វើអីគេទៅ?

ស៊ីលឿត ៖ ទៅនៅធ្វើដូចធម្មតាចេះឯង ។

ឈុនលី ៖ ហើយហូបចុកអីម៉េចទៅរស់នៅហ្នឹង?

ស៊ីលឿត ៖ ហូបចុកកាលនោះដូចគេមិនទាន់បើកអីឲ្យយើងរកដំឡូងអីទៅហូបទៅណាស អាទៅនៅត្រពាំងវែងបានហូបបាយរួម ។

ឈុនលី ៖ ចុះអង្ករអីៗនោះ?

ស៊ីលឿត : អង្ករយើងរកទៅ ។

ឈុនលី : គេអត់ចែកឲ្យទេ?

ស៊ីលឿត : អង្ករហ្នឹងគេចែកឲ្យ ខ្ញុំចាំអត់អស់ដែរបើកាលនោះមិនទាន់ពេញវ័យផងប្រហែលជាបីដណ្ដប់ មិនទាន់គ្រប់ការផង នៅក្មេងនៅតែរៀននៅឡើយ ។ ដល់រួចពីនោះទៅទៅនៅត្រពាំងវែង ។ ទៅប្រពាំងវែងបានប្រហែលម៉ាខែពីរខែបានជម្លៀសអ្នកថ្មីមក ពីភ្នំពេញមកណាស ។ អ្នកភ្នំពេញមកខ្ញុំក៏ចុះធ្វើខាងនារីមិនទាន់គ្រប់ការទេ ។

ឈុនលី : អ្នកភ្នំពេញដែលមកជាមួយ ពូឃុ ហ្នឹងហ្អី?

ស៊ីលឿត : នោះឯង ពួកនោះឯងតែមិនដឹងឆ្នាំណាកាលមកនោះ ។

ឈុនលី : ចុះខ្មែរក្រហមចូលមកយូរហើយនៅបានពួកគាត់មក?

ស៊ីលឿត : ទេ មិនដល់ម៉ាឆ្នាំទេដឹងកាលនោះ ។

ឈុនលី : នៅឆ្នាំ៧៥ នៅឡើយ?

ស៊ីលឿត : ចា៎!ខ្ញុំចាំបានខ្លះមិនបានខ្លះបើមិនទាន់ពេញវ័យនៅប៉ុនណេះមិនទាន់គ្រប់ការផងនោះដល់មក
ពីនោះក៏ពួកខ្មែរក្រហមគេហៅប្រជាជនថ្មីក៏ជម្លៀសខ្ញុំទៅនៅអាងត្រពាំងថ្មទៅលើកទំនប់អីណោះ ។

ឈុនលី : ពេលប្រជាជនថ្មីមកបានគេរៀបសហករណ៍ឬយ៉ាងម៉េច?

ស៊ីលឿត : សហករណ៍មុន មុនប្រជាជនថ្មីមក កាលនោះគេឈប់បើកអង្ករហូបហើយណាស ។ ដល់ប្រជាជនថ្មីបានថាមិនដឹងបានប៉ុន្មានខែឬប៉ុន្មានឆ្នាំបានគេបាយរួមសាមសិបគ្រួសារ១ចឹងទៅ ។

ឈុនលី : ដូចយើងប្រជាជនចាស់អីចឹងមានទំនាស់ជាមួយប្រជាជនថ្មីទេ?

ស៊ីលឿត : ខ្ញុំមិនដែលមានទេ មានតែថាបានដំឡូងបានអីមកក៏ចែកគ្នាហូប ។

ឈុនលី : ហើយអ្នកថ្មីៗហ្នឹងពិបាកទេមក?

ស៊ីលឿត : ចុះ គ្នាអ្នកភ្នំពេញចឹងម៉េចចេះស្ទូងចេះដក ដូចថាអ្នកស្រែយើងចេះកាប់ដីអី គ្នាមិនសូវចេះទេ ។ ដូចពួកយើងអ្នកចាស់ចឹងចេះតែប្រាប់ទៅខ្លាចគេយកទៅវៃចោលនោះចេះតែនាំគ្នាទៅៗ ពួកខ្ញុំបានអីក៏ចែកគ្នាហូបទៅ ។

ឈុនលី : ចុះមុនពេលទៅត្រពាំងថ្មហ្នឹងទៅណាសិនទៅលើកគំនប់អីផ្សេងទៀតអត់?

ស៊ីលឿត : ត្រពាំងថ្មហ្នឹង លើកប្រព័ន្ធស្រែយើងហ្នឹងតាមវាល តាមស្រែតូចៗ ។

ឈុនលី : ចុះនៅស្រះអីហ្នឹងក្រែងមានទំនប់មួយដែរហ្អី?

ស៊ីលឿត : ស្រះមាន!

ឈុនលី : ចុះមីងលើកដែរអត់?

ស៊ីលឿត : ខ្ញុំលើកដែរ ខ្ញុំមកពីត្រពាំងថ្មរួចបានទៅស្រះ ស្រះយើងនេះ ។

ឈុនលី : មិនមែនលើកពីស្រះហើយទៅត្រពាំងថ្មទេ?

ស៊ីលឿត : ទេ!ខ្ញុំពីត្រពាំងថ្មសិនៗ វាមានពីរផ្នែកណាស ស្រះផ្សេង ត្រពាំងថ្មផ្សេងៗ កំបោភ្នំស្រះ ខ្ញុំត្រពាំងថ្មអាងត្រពាំងថ្ម លើកដីលើកអីនោះណាសដល់ចប់ទៅបានគេ បញ្ជូនខ្ញុំមកនេះ រន្ទះបាញ់ ។

ឈុនលី : ឆ្នាំណាដែលគេចាប់ផ្ដើមលើកនៅត្រពាំងថ្ម?

ស៊ីលឿត : ខ្ញុំចាំមិនបានទេកាលនោះ ។

ឈុនលី : តែមីងអាចស្មានបានទេ ប្រហែល៧៥ ៧៦ ៧៧?

ស៊ីលឿត : ស្មានទៅខ្លាចស្មានខុសទៅមិនហ៊ានស្មានទេ!

ឈុនលី : តែខ្មែរក្រហមចូលមកយូរទេ?

ស៊ីលឿត : ចូលមកបានប្រហែលម៉ាឆ្នាំ ។

ឈុនលី : ហើយទៅគ្នាច្រើនទេ?

ស៊ីលឿត : ហូស!គ្នាច្រើនណាស់មិនចេះតិចទេ ។

ឈុនលី : ប្រហែលប៉ុន្មានរយប៉ុន្មានពាន់ទៅ?

ស៊ីលឿត : រាប់ពាន់នាងអើយ!អាគេក៏លើក អាយើងក៏លើកមើលទៅឡើងទំនប់ប៉ុណ្ណណើ ។

ឈុនលី : អ្នកយាំងម៉េចខ្លះដែលគេឲ្យទៅលើកទំនប់ត្រពាំងថ្ម?

ស៊ីលឿត : អានេះគេកេណ្ឌពួកនារីយុវជន ឲ្យតែនារីយុវជនទៅទាំងអស់ កុមារគេឲ្យនៅតាមភូមិ ។ ខ្ញុំនារីយុវជនទៅទាំងអស់ទៅលើក ។ អាងត្រពាំងថ្ម អាងកូនខ្វែងក៏ទៅលើកទៀត ។ មកពីនោះគេឲ្យលើកនៅរន្ទះបាញ់ ។

ឈុនលី : អីចឹងលើកម៉ាហើយបាន៣គេឲ្យមកវិញ?

ស៊ីលឿត : ចាំ!ម៉ាហើយណាស!

ឈុនលី : ប្រហែលរយៈពេលប៉ុន្មានទៅ?

ស៊ីលៀត ៈ ហួស!រាប់ខែនោះនាងបើធ្វើអាស្ពានទឹកស្ពានអី ។ ធ្វើអាស្ពានទឹកនេះគ្រាន់តែលើកបាន អាងត្រពាំងថ្មនេះ អាស្ពាននេះប្រុសៗគេធ្វើ ពួកខ្ញុំគេបញ្ជូនមកអីចេះទៅលើកនៅរទេះ បាញ់ ។

ឈុនលី ៈ ហើយអាងនោះធំទេ?

ស៊ីលៀត ៈ ធំណាស់ត្រពាំងថ្ម ។

ឈុនលី ៈ ទទឹងបណ្ដោយប៉ុន្មានទៅ?

ស៊ីលៀត ៈ មិនដឹងប៉ុន្មានទទឹងបណ្ដោយ ធំណាស់ខែវស្សាជងគួរឲ្យខ្លាច ។

ឈុនលី ៈ ហើយកំពស់ប៉ុន្មានទៅ?

ស៊ីលៀត ៈ កំពស់ប៉ុន្មានម៉ែត្រទេទំនប់នោះ ទទឹងប្រហែល៥ម៉ែត្រ ។ ទទឹងក៏ធំកំពស់ក៏ខ្ពស់រែកឡើង ចង់ងាប់ ។

ឈុនលី ៈ រែកឡើងទៅលើ?

ស៊ីលៀត ៈ រែកឡើងលើទៀតណាស ហើយយើងដើររែកឡើងលើទៀត ។

ឈុនលី ៈ អីចឹងមិនត្រូវរែកពីក្រោមឡើងទៅលើទៀត?

ស៊ីលៀត ៈ ជំរៅបើគេឲ្យយើងជីកម៉ាម៉ែត្រគីបក៏ម៉ាម៉ែត្រគីបទៅ ។ ជំរៅម៉ាម៉ែត្រ ទទឹងម៉ាម៉ែត្រ បណ្ដោយម៉ាម៉ែត្រ ម៉ាម៉ែត្រគីប ។

ឈុនលី ៈ អីចឹងរាក់ហ្នឹងអាងហ្នឹង?

ស៊ីលៀត ៈ ទេ អាអាងហ្នឹងផ្សេងយើងជីកដីក្រៅណាស ក្នុងអាងហ្នឹងក៏ជីកដែរ ។ ក្នុងអាងជ្រៅ ណាស់ណា គេធ្វើទ្វារទឹកជ្រៅពីរបីម៉ែត្រណោះណាស ។ បើខ្ញុំយកដីដាក់ក្រៅទេ តែអា ក្នុងអាងក៏ជីកដែរ ។

ឈុនលី ៈ អ្នកណាគេអ្នកជីកនៅក្នុងមិនមែនមីងទេ?

ស៊ីលៀត ៈ អត់ទេខ្ញុំជីកអាក្រៅ ហើយមិនមែនមានតែម៉ាពួកទេណាស វាមានច្រើនពួកច្រើនភូមិ នៅភូមិនេះភូមិនោះដង្ហែគ្នាទៅ ។

ឈុនលី ៈ ហើយម្នាក់គេឲ្យប៉ុន្មានជីក២ម៉ែត្រ?

ស៊ីលៀត ៈ ក្នុងម្នាក់ដូចថា ម៉ាក្រុមយើងដប់នាក់អីចឹងណាស ប៉ុន្មានម៉ែត្រគីបរួចពីរម៉ែត្រគីប ។ ពីរ ម៉ែត្រគីបទទឹងពីរមែត្រ បណ្ដោយពីរម៉ែត្រ ជំរៅម៉ាមែត្រពីរម៉ែត្រទាំងអស់ ៗ ។

ឈុនលី ៈ ម្នាក់ហ្អី?

ស៊ីលៀត ៈ អត់ទេម៉ាក្រុមដប់នាក់ឲ្យយើងជីកលើក ។

ឈុនលី ៖ ម៉ាងៃហ្អី?

ស៊ីលឿត ៖ បើយើងហើយពីថ្ងៃគេតំឡើងទៀត យើងស្រីៗនេះខំជីកចង់ងាប់ ប្រុសៗមិនសូវទេ ។ ស្រីៗខំជីក ហើយថ្ងៃឡើងថែមម៉ាម៉ែត្រទៀត ជីកម៉ាក្រុមទៀតយប់ឡើងធ្វើការទៀត ។

ឈុនលី ៖ ធ្វើយប់ទៀតពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

ស៊ីលឿត ៖ ម៉ោងប្រាំហូបបាយទៅក៏ម៉ោងប្រាំមួយចុះធ្វើការទៀត ។ យើងស្រីៗធ្វើដល់ម៉ោងដប់ យប់ម៉ាដណ្តប់ ។

ឈុនលី ៖ ចុះអាពេលព្រលឹមឡើងទៅធ្វើការម៉ោងប៉ុន្មាន?

ស៊ីលឿត ៖ ភ្លឺឡើងប្រហែលម៉ោង៧ ។

ឈុនលី ៖ ចុះស្មើណាហូបបាយ?

ស៊ីលឿត ៖ ម៉ោងម៉ាដណ្តាប់ ។

ឈុនលី ៖ បាយប៉ុន្មានពេល?

ស៊ីលឿត ៖ បាយម៉ាពេលប៉ុណ្ណឹងឯង បាយនឹងប្រហុក បាយម៉ាពេល ។

ឈុនលី ៖ មិនមែនបបរទេ បាយ?

ស៊ីលឿត ៖ បាយ ។

ឈុនលី ៖ អត់មានអីហូបទេ?

ស៊ីលឿត ៖ អត់ទេ មានតែប្រហុកកូរនឹងទឹកខាប់ៗទៅបេះអន្ទក់ខ្លួនយើង ។

ឈុនលី ៖ ដូចទឹកគ្រឿង?

ស៊ីលឿត ៖ ចាំ!ជួនកាលទៅគេចែកអំបិលឲ្យយើងទៅ ។

ឈុនលី ៖ មិនមែនស្លរទេ?

ស៊ីលឿត ៖ អត់ទេ ។

ឈុនលី ៖ រោងបាយគេនៅទីនោះ?

ស៊ីលឿត ៖ រោងបាយចុងភៅគេមានដាំឲ្យយើងក្នុងម៉ាក្រុមគេដាំឲ្យយើងទៅ តែអារឿងថាលើកនោះ យ៉ាប់ហ្នឹងឯងយើងស្រី ។

ឈុនលី ៖ ចុះទឹកហូបមានទេ?

ស៊ីលឿត ៖ ទឹកមានតែវាឆ្ងាយ ។

ឈុនលី ៖ ចុះទឹកមុជ?

ស៊ីលឿត ៖ ទឹកមុជមិនមានទេ ពីរថ្ងៃបីថ្ងៃបានមានម្តង មានតែឆ្ងាយចុះលើកខែចេត្រ ។

ឈុនលី ៖ ក្តៅ?

ស៊ីលឿត ៖ អូស! ក្តៅណាស់អាខែយើងច្រូតរួចហ្នឹងលើក ខែភ្លៀងហ្នឹងក៏លើកដែរ ។

ឈុនលី ៖ ខែភ្លៀងលើកទៅមិនអ៊ាចសុទ្ធតែទឹក?

ស៊ីលឿត ៖ ទឹកហើយ តែមិនដឹងធ្វើម៉េចចេះតែបន្លូរទៅ ។

ឈុនលី ៖ តែមីងអត់ដែលចុះទៅដល់អាជីវៅក្រោមទេ?

ស៊ីលឿត ៖ ចុះដូចគ្នា បើគេថាជីកទៅក្រោមដមាំម៉ែត្រជីកទៅ ជួនកាលពីលើមកក្រោមមានបីម៉ែត្រ ក៏មាន បួនម៉ែត្រក៏មានធ្វើដណ្តើរឡើងពីក្រោមដល់ខែភ្លៀងអីផងយ៉ាប់ណាស់ រអិល ។

ឈុនលី ៖ អីចឹងមិនយឺត?

ស៊ីលឿត ៖ ចាំ! យឺត ។

ឈុនលី ៖ ហើយធ្វើដល់ម៉ោងដប់យប់ស្មើរណាបានៗសំរាក?

ស៊ីលឿត ៖ ហ៊ឹស! មិនដែលដេកបានស្រួលផង ដូចថាភ្លឺចឹងក្រោកពីយប់ដើរក្តិចណាស់ ប្រធានកង ស្រីៗដើរក្តិចពួកខ្ញុំឲ្យក្រោក ។

ឈុនលី ៖ អ្នកណាគេប្រធានកង?

ស៊ីលឿត ៖ ប្រធានកងមិននៅទីនេះទេមិនដឹងបាត់ខ្លួនទៅខាងណាទេ ខាងខ្មែរក្រហម ។

ឈុនលី ៖ អ្នកស្រុកណាវិញ?

ស៊ីលឿត ៖ អ្នកស្រុកនេះឯងប្រធានកង ។

ឈុនលី ៖ ស្គាល់ឈ្មោះទេ?

ស៊ីលឿត ៖ មិនស្គាល់ទេបើបាត់យូរហើយមិនដឹងជារស់ឬស់ទេ ។

ឈុនលី ៖ តែកាលនោះស្គាល់ទេ?

ស៊ីលឿត ៖ ស្គាល់ តែគេប្រែឈ្មោះប្រែអីមិនដែលប្រើឈ្មោះពិតទេ ។

ឈុនលី ៖ ចុះកាលនោះគេប្រើឈ្មោះអី?

ស៊ីលឿត ៖ កាលនោះគេហៅឈ្មោះសឿនៗ ឈ្មោះឡាច គាត់ឈ្មោះឡាច ។

ឈុនលី ៖ ស្រី?

ស៊ីលឿត ៖ ស្រី!

ឈុនលី ៖ អ្នកស្រុកណា?

ស៊ីលឿត ៖ អ្នកស្រុកនេះ ប៉ុន្តែអ្នកស្រុកនេះជម្លៀសដូចគ្នាំណាសដូចថាមកពីចំងាយអីចេះណាសដល់មកនៅស្រុកភូមិនេះទៅគេដាក់ឈ្មោះ ឡាច តែមិនដឹងឈ្មោះអីទេ ដល់យួនចូលក៏មិនដឹងទៅណាទេ ។

ឈុនលី ៖ មិនមែននៅព្រះនេត្រព្រះទេវ?

ស៊ីលឿត ៖ អត់ទេ!ប្រធានកងមិនដែលមានអ្នកព្រះនេត្រព្រះទេ?

ឈុនលី ៖ អ្នកនិរតីហ្អី?

ស៊ីលឿត ៖ តាកែវហ្អី គេថាពួកពាយ័ព្យចូលមក ។

ឈុនលី ៖ ចុះពេលណាបានពួកនិរតីចូលមក?

ស៊ីលឿត ៖ និរតីចូលមកមិនដឹងឆ្នាំណាទេ ខ្ញុំចាំមិនបាន ។ យើងមិនទាន់បានធំឲ្យដឹងក្តីទេ លើកដីឡើងអាយុប្រាំមួយដណ្តប់ ប្រាំដណ្តប់បានដឹងក្តី ។

ឈុនលី ៖ ពិបាកអីខ្លះទៅមីងធ្វើការនៅទីនោះ?

ស៊ីលឿត ៖ ហ្អស!អាពិបាកនេះរឿងលើកដី ពិបាកអារឿងស៊ីចុកអីយ៉ាប់ យើងមិនដែលបានឆ្អែត យើងមិនមានកំលាំងធ្វើការ ឈឺក៏មិនដែលហ៊ានឈប់ដែរ រាគរួសយ៉ាងណាក៏សុំថ្នាំគេលេបបានខ្លះ ។

ឈុនលី ៖ ថ្នាំអីគេ?

ស៊ីលឿត ៖ ថ្នាំអាចន៍ទន្សាយ ចត់ៗ ផ្អែមៗប៉ុណ្ណោះ ។

ឈុនលី ៖ ចុះមីងអស់ស្គាល់អ្នកដែលនៅធ្វើការនៅទីនោះទេ?

ស៊ីលឿត ៖ អត់ស្គាល់ទេ ស្គាល់ក៏មិនដឹងគេទៅនៅខាងណាអស់ដែរ ដែលហ៊ាននៅស្រុកនេះហ្អស អ្នកធ្វើប្រធានកងប្រធានអីនោះ ។ មិនមាននៅមិនដឹងគេទៅនៅខាងណាទេ ។

ឈុនលី ៖ អីចឹងអាងហ្នឹងជីកទៅមិនប៉ុណ្ណាណីហើយ?

ស៊ីលឿត ៖ រាប់ខែណាសជីកអាងនោះបានរួច ប៉ុណ្ណាណី ។

ឈុនលី ៖ បើគិតទៅប៉ុន្មានហ្នមីង ប្រវែង?

ស៊ីលឿត ៖ ខ្ញុំស្មានមិនដឹងទេអាងត្រពាំងថ្មធំណាស់ មើលទៅដាច់កន្ទុយភ្នែកទៅដើង ។

ឈុនលី ៖ គេជីកដើម្បីអី?

ស៊ីលឿត ៖ មិនដឹងដែរគេថាជីកអាងត្រពាំងថ្មដើម្បីយកទឹក ធ្វើទ្វារទឹកធ្វើអីទៅណាស ។

ឈុនលី ៖ នៅទីនោះអត់មានទឹក?

ស៊ីលឿត ៖ ពីដើមមិញអត់មានទេដីស្រែធម្មតា ដល់សម័យ អាពត ទៅគេធ្វើអាង ។

ឈុនលី ៖ អីចឹងពេលដែលមីងទៅជីកហ្នឹងវាលសុទ្ធតែម្ដងហ្អី?

ស៊ីលឿត ៖ វាលសុទ្ធ វាលស្រែយើងសុទ្ធចេញពីភូមិត្រពាំងថ្មមកវាលសុទ្ធ ចំងាយពីភូមិប្រហែលពីរបីគីឡូ ។

ឈុនលី ៖ អីចឹងមីងជីក...ខ្ញុំអត់សួរយល់ ជីកហើយលើកដីមកដាក់នៅឯលើ?

ស៊ីលឿត ៖ គេវាស់តំនប់អីចេះ វាស់ឲ្យយើងជីកដីចំងាយបីម៉ែត្រពីជើងទំនប់អីចេះ ។ គេវាស់ម៉ែត្រគឺបឲ្យយើងណាស ក្នុងបីម៉ែត្រគឺបម៉ាក្រុមដប់នាក់ចឹងណាស បណ្ដោយបីម៉ែត្រ ទទឹងក៏បីម៉ែត្រ ជំរៅទៀត?

ឈុនលី ៖ ជំរៅម៉ាម៉ែត្រ?

ស៊ីលឿត ៖ ចាំ!ម៉ាម៉ែត្របើមិនគ្រប់យើងដាក់បីម៉ែត្រទេ ដូចថាម៉ាម៉ែត្រគឺបណាសដល់ពេលជ្រៅយើងធ្វើជណ្ដើរប៉ុណ្ណេះពីក្រោមឡើងមកលើ ។

ឈុនលី ៖ ឡើងទៅចាក់?

ស៊ីលឿត ៖ ឡើងនៅអីលើទៀត ។

ឈុនលី ៖ បើគិតទៅកំពស់លើប៉ុន្មាន?

ស៊ីលឿត ៖ កំពស់ប្រហែលជាបីម៉ែត្របួនម៉ែត្រ ។

ឈុនលី ៖ បន្ដីធំៗ?

ស៊ីលឿត ៖ បន្ដីរប៉ុណ្ណេះ!

ឈុនលី ៖ ហើយមានអ្នកណាដែលកំពុងធ្វើការហើយដួលទេ ដូចថាលើកដីលើកអី?

ស៊ីលឿត ៖ វាមានតើមានដួលមានអីក៏ចាប់ខ្យល់ចាប់អីឲ្យគ្នាទៅ ។

ឈុនលី ៖ គេអត់ថាអីដែរហ្អី?

ស៊ីលឿត ៖ ដល់យើងឃើញអីចឹងទៅប្រាប់មេកោយទៅគេឲ្យយើងសំរាក់ចាប់ខ្យល់ទៅ ជាទៅធ្វើការទៀត បើយើងធ្វើមិនរួចទេគេឲ្យទៅដេកនៅក្នុងខ្ទម ។

ឈុនលី ៖ ចឹងគេអត់មានតឹងតែងជាមួយយើងទេ?

ស៊ីលឿត ៖ អត់ទេ បើថាគេមើលឃើញដាក់ស្ដែងបានគេឲ្យយើងទៅដេកខ្ទម បើថាមើលទៅមិនដាក់ស្ដែងគេឲ្យយើងខំឲ្យរួច ។ អីចឹងឯងទៅបត់ជើងបត់អីបើថាយើងមួលអីចេះ គេទៅមើលសិន បើថាគេឃើញមួលឃើញឈាមគេឲ្យយើងសំរាក គេខ្លាចយើងកុហកគេអត់ធ្វើការ ។ បើពួកខ្ញុំលើកទៅឃើគាក់តិចអីមិនហ៊ានឈប់ទេចេះតែទៅៗលើកឡើងរួចអីណោះ ។

ឈុនលី ៖ តែអ្នកធ្វើការនៅទំនប់ដឹងតែឲ្យហូបបាយហើយ?

ស៊ីលឿត ៖ ហូបបាយតែមិនមែនបាយស្រួយយើងទេនាង បាយបុិៗនោះណាសតែប៉ុណ្ណឹងគ្នាអរចង់ងាប់ ។

ឈុនលី ៖ ហូបតែជាមួយប្រហុកទេ?

ស៊ីលឿត ៖ ប្រហុក គេចែកអំបិលខ្លះ ។

ឈុនលី ៖ អត់ដែលមានសម្លរទេ?

ស៊ីលឿត ៖ អត់ទេ អត់មានសម្លទេចែកអំបិលចឹងទៅ ។ យើងទៅរកក្តាម ខ្យងនៅតាមស្រែមកធ្វើខ្លួនយើងទៅណាស ។

ឈុនលី ៖ គិតទៅដឹកម៉ាឆ្នាំទេមីង?

ស៊ីលឿត ៖ ទេ មិនដល់ម៉ាឆ្នាំទេដឹកនោះបើធ្វើការទាំងយប់ទាំងថ្ងៃមិនដល់ម៉ាឆ្នាំទេ ។

ឈុនលី ៖ គេក៏ដឹកទាំងយប់ដូចយើងដែរហ្អី?

ស៊ីលឿត ៖ ទាំងអស់តែគ្នាហ្នឹង ឧទាហរណ៍ថាគេដាក់បីម៉ែត្រគឺបបើយើងរួចក៏យើងសំរាកទៅណាស ។ មុននឹងសំរាកក៏ម៉ោងដប់ម៉ាដណ្តប់ទៅណាសទំរាំតែយើងរួច ។

ឈុនលី ៖ ចុះម៉ាថ្ងៃពីព្រឹកមកដល់ល្ងាចអត់ទាន់ហើយ?

ស៊ីលឿត ៖ អត់ទាន់ហើយបើគ្នាស្រីៗកំលាំងតិចអត់ទាន់ហើយទេ មានប្រុសមានអីទៅគេហើយមុនយើងទៅណាស ស្រីៗមិនសូវបានកំលាំងដូចគេទេគេហើយម៉ោងប្រាំ យើងក៏ម៉ោង៧/៨ បានហើយបានដេក ។

ឈុនលី ៖ ចុះធ្វើការយប់អីចឹងគេមានបន្ថែមមានអីឲ្យដែរអត់?

ស៊ីលឿត ៖ ទេ មិនដែលមានទេ ។

ឈុនលី ៖ អត់ដែលមានសោះម៉ងហ្អី?

ស៊ីលឿត ៖ ទេ មិនដែលមានទេ បានតែបាយឆ្អែតអរចង់ងាប់ទៅរកបន្ថែម... ។ ពួកខ្ញុំមិនដែលបាននៅផ្ទះជាមួយម៉ែឪទេ ទៅទំនប់មកវិញមិនដែលបានចូលភូមិផង ចូលមកយ៉ាងណាបានម៉ាថ្ងៃគេឲ្យទៅទៀតហើយលើក ។

ឈុនលី ៖ ចុះម្តាយឪពុកមីងនៅហ្នឹង?

ស៊ីលឿត ៖ នៅនេះឯងនៅភូមិត្រពាំងវែង ។ ម៉ែខ្ញុំ...ឪក៏ដាក់ទ្រូដាក់អីធ្វើអាជីវកម្មហ្នឹងណាស យកម្ហូបយកអីមកឲ្យអ្នកស្ទួង ។ បានម៉ែឪខ្ញុំនេះឯងបានបាយលួចបាយលួចអីបានផ្ញើរទៅឲ្យលីងបាយក្រៀមបាយអីយកទៅឲ្យ ។

ឈុនលី ៈ ចុះម៉េចក៏គាត់បានស្ករបានអីចឹង?

ស៊ីលឿត ៈ ស្ករ យើងស្គាល់គ្នាជាមួយអ្នកធ្វើស្ករយើងយកដំឡូងទៅឲ្យគេ គេឲ្យស្ករមកវិញដូរគ្នាបាន បានហូប ។ យូរគ្រាន់ដែរមកដល់ផ្ទះបានបបររួមសាមសិបគ្រួសារបបរពាវហូបមិនឆ្អែត ។

ឈុនលី ៈ ចុះបើគិតទៅជីកបានមួយឆ្នាំទេ?

ស៊ីលឿត ៈ មិនដល់ទេ!ទំនប់លើកលឿនណាស់ណា គេវ៉ៃសំរុកទាំងយប់ទាំងថ្ងៃបើផែនការវាបីខែឲ្យរួចយើងត្រូវឲ្យបីខែរួច ។

ឈុនលី ៈ ផែនការគេគឺបីខែ?

ស៊ីលឿត ៈ ផែនការវាមិនដឹងប៉ុន្មានបីខែឬបួនខែឲ្យរួច ។ ឲ្យឧទាហរណ៍ថា ផែនការបីខែឲ្យរួច យើងត្រូវលើកបីខែឲ្យរួចនឹងអាលបញ្ជូនយើងទៅណាទៅណីទៀតចឹងណាសមិនមែនលើកបណ្តោយតាមតែយើងលើកបានទេ ។

ឈុនលី ៈ ខ្ញុំឮអ្នកខ្លះថាឲ្យជីកបីម៉ែត្រគីប?

ស៊ីលឿត ៈ បីម៉ែត្រគីប ឧទាហរណ៍ថាយើងលើករួចអីចេះ...

ឈុនលី ៈ ម្នាក់?

ស៊ីលឿត ៈ ពួកខ្ញុំម៉ាក្រុមបីម៉ែត្រគីប ។

ឈុនលី ៈ ភាគច្រើនគេចែកអីចឹងហ្អី?

ស៊ីលឿត ៈ ចា៎! ម្នាក់បីម៉ែត្រគីប ផាប់ណាស ។ ក្រុម ចែកតាមក្រុម ក្រុមយើងប៉ុន្មាននាក់ដប់នាក់ ឬក៏ប្រាំនាក់ ហ្អក!មិត្តឯងបីម៉ែត្រគីបឲ្យរួចអីចេះ យើងខំទៅ ។

ឈុនលី ៈ ម៉ាក្រុមដប់នាក់?

ស៊ីលឿត ៈ ចា៎!

ឈុនលី ៈ មានស្រីមានប្រុសអីចឹងទៅ?

ស៊ីលឿត ៈ ពួកខ្ញុំ មានតែស្រីៗកំរមានប្រុសណាស់ មានតែស្រីៗ ។

ឈុនលី ៈ ចុះពេលជីកហ្នឹងពេលណាមានភ្លៀងមិនទឹកពេញហ្នឹងហើយ?

ស៊ីលឿត ៈ ទឹកពេញទៅបង្ហូរ ។

ឈុនលី ៈ បង្ហូរម៉េចបើវានៅពេញហ្នឹង?

ស៊ីលឿត ៈ បើនៅក្នុងអីចឹងគេឲ្យយើងសំរាកសិន ទៅជីកនៅកន្លែងផ្សេងទៀតទោះបីជាភ្លៀងយ៉ាងណាក៏គេនៅតែប្រើយើងទៀត ។

ឈុនលី ៈ ធ្វើហាលភ្លៀងម៉ង?

ស៊ីលៀត ៖ ហាលភ្លៀង ។

ឈុនលី ៖ ចឹងអត់ខ្លាចរន្ទះអីទេ?

ស៊ីលៀត ៖ មិនខ្លាចអីទេកាលនោះ ហាលភ្លៀងទៅ ជួនកាលដេកទាំងភ្លៀងទៅក៏មាន ធ្វើការៗយប់ទៅដេកទាំងភ្លៀងក៏មាន ចុះមានអីនឹងគ្របកន្លែងដេកនោះ ព័ទ្ធកៅស៊ូក៏រ៉ុះៗ ខ្ទមតូចវែងដេកទល់ក្បាលគ្នា ។

ឈុនលី ៖ ចៃហើយឆ្លងចៃឆ្លងអី?

ស៊ីលៀត ៖ ទេ ដូចមិនមានចៃទេនាំគ្នាកក់សាប៊ូអ្នកភ្នំពេញគេមកបានសាប៊ូមកណាស បានពួកនោះឯងឲ្យសាប៊ូកក់សក់ សាប៊ូបោកខោអាវយើងណាសកក់អាហ្នឹង ។ កាលនោះដូចមិនសូវមានចៃមានអីផង ម៉ាអាទិត្យបានបានមុជទឹកណាស ម៉ាអាទិត្យ បីដង ។

ឈុនលី ៖ ចឹងមិនស្អិតខ្លួនពេញហ្នឹងហើយ?

ស៊ីលៀត ៖ ស្អិតក៏មិនដឹងធ្វើម៉េចដេកទាំងអីចឹងហើយ អាខោក៏ប្រឡាក់ប្រឡូសមិនដែលបានបោកខោទេម៉ាអាទិត្យ ។ ពីនោះទៅប្រហែលម៉ាគីឡូទៅមុជទឹក វាឆ្ងាយមិនមែនជិតទេ ។

ឈុនលី ៖ ចុះអត់ដែលមានពេលណាសំរាកទេ?

ស៊ីលៀត ៖ គ្មានទេ បើថ្ងៃណាសំរាកបើកអង្គមេទ្ទីញគេឲ្យយើងសំរាកទៅណាស ។

ឈុនលី ៖ ចុះអាពេលទៅដីកហ្នឹងមានបើកអង្គមេទ្ទិញដែរ?

ស៊ីលៀត ៖ ដីក បើកតើ ទៅធ្វើការបើកអង្គមេទ្ទិញដូចថាគេប្រដៅយើងកុំឲ្យខ្ជិលច្រអូសអីចេះមួយអីចុះមួយទៅណាស បង្រៀនយើងពីរឿងសីលធម៌អ្នកណាខុសសីលធម៌គេវ៉ៃអីចឹងទៅណាសកុំឲ្យគេវ៉ៃចឹងទៅណាសកុំឲ្យយើងស្រលាញ់គ្នាចឹងណាស ។

ឈុនលី ៖ មីងបានឃើញអាកាលគេវ៉ៃនៅជិតវត្តនេះទេ?

ស៊ីលៀត ៖ ឃើញ ឃើញគេវ៉ៃតើ ។

ឈុនលី ៖ មកមើលដែរ?

ស៊ីលៀត ៖ មក ។

ឈុនលី ៖ យ៉ាងម៉េចខ្លះទៅមីង?

ស៊ីលៀត ៖ កាលនោះគេចង អើ!ខាងណេះមួយខាងណោះមួយគេចងទាំងពីរនាក់ហ្នឹង ។ គេវ៉ៃ ខ្ញុំងាកមុខចេញមិនហ៊ានមើលទេ ។

ឈុនលី ៖ អីចឹងមិនស្រែកហើយ?

ស៊ីលៀត ៖ អត់ស្រែកទេ គេឲ្យអោនគ្នាក៏អោនមុខ តែមនុស្សស្រីឡើងបីដងបង ។

ឈុនលី ៖ ប៉ុន្មានដងបង?

ស៊ីលឿត ៖ បីដងបងមនុស្សស្រី ។

ឈុនលី ៖ វ៉ៃកន្លែងណាទៅ?

ស៊ីលឿត ៖ វ៉ៃកន្លែងកនេះ វ៉ៃម៉ាដងបងមិនងាយងាប់ទេអ្នកមានកូន ។

ឈុនលី ៖ ម៉េចចឹង?

ស៊ីលឿត ៖ ដង្ហើមកូន អត់ងាយងាប់ទេ បើអាប្រុសងាកចេះទៅដាក់ទៅងាប់បណ្ដោយ ។

ឈុនលី ៖ ហើយស្រីហ្នឹងឃើញគេវ៉ៃប្ដីមិនស្រែកហើយ?

ស៊ីលឿត ៖ អត់ហ៊ានស្រែកទេគ្រាន់តែមុខខ្មៅបែបមិនរស់ទេ ។ អ្នកមើលអង្គុយដូចយើងចឹង ចុះចង បង្គោល...

ឈុនលី ៖ មើលឆ្ងាយហ្អី?

ស៊ីលឿត ៖ ទេ មិនឆ្ងាយទេប្រហែលពីនេះទៅស័ក្ដសីនោះ គេអង្គុយមើលឡើងពេញដល់ពេលវ៉ៃទៅខ្ញុំងាកមុខចេញ ។

ឈុនលី ៖ ហើយគេស្រែកថាម៉េចទៅ គេប្រាប់ថាម៉េចទៅ?

ស៊ីលឿត ៖ ប្រាប់ថាពីរនាក់នេះខុសសីលធម៌ស្រឡាញ់គ្នាឡើងមានកូនទំងន់ប៉ុន្មានខែ ។ គេយកមកវ៉ៃឲ្យយើងមើលកុំឲ្យយើងធ្វើតាម ចឹងទៅក៏គេងាកមុខចេញ ។

ឈុនលី ៖ អ្នកស្រុកណាទៅមីង?

ស៊ីលឿត ៖ មិនមែនពួកអ្នកចាស់ទេកាលនោះ ដូចជាមកពីឆ្ងាយដែរមិនមែនអ្នកស្រុកនេះទេ ។ តែស្រីហ្នឹងមានប្ដីហើយ ។

ឈុនលី ៖ ចុះប្រុសហ្នឹង?

ស៊ីលឿត ៖ ប្រុសហ្នឹងមិនដឹងគេមានប្រពន្ធដែរអត់ខ្ញុំមិនដឹងដែរគ្រាន់តែឃើញគេបណ្ដើរមកវ៉ៃទាំគ្នាតក់ស្លុតទាំងអស់គ្នាមានអ្នកណាហ៊ានមើល គេវ៉ៃហ្នឹងងាកមុខចេញទាំងអស់គ្នា មិនហ៊ានយំមិនហ៊ានស្រែកទេខ្លាចគេ ឬស្សីឡើងប៉ុណ្ណេះ ។

ឈុនលី ៖ អីគេប៉ុណ្ណឹង គល់ឬស្សី?

ស៊ីលឿត ៖ គល់ឬស្សីធំ ថាម៉ាពើសទៅហើយមនុស្សស្រី បើមនុស្សប្រុសស្រីវានៅ នៅផ្ទក់ៗដង្ហើមដែលមានកូនក្នុងពោះនោះមិនងាយងាប់ទេ ហើយបានគេស្រាយយកទៅណាទៅណីគេរំសាយយើងកុំឲ្យយើងរយីងរយ៉ាងតាម ។

ឈុនលី ៖ កាលនោះយើងស្លៀកខោឬស្លៀកសារ៉ុង សំពត់?

ស៊ីលឿត ៖ ស្បៀកខោ ស្បៀកខោជ្រលក់នឹងសំបកគ្រស់សំបកស្នួល ។

ឈុនលី ៖ ស្បែកជើង?

ស៊ីលឿត ៖ ស្បែកជើងទាល់តែពួកនិរតីមកបានស្បែកជើងកង់ឡាន ។

ឈុនលី ៖ ចុះយើង?

ស៊ីលឿត ៖ យើងធម្មតាអ្នកខ្លះមានអ្នកខ្លះក៏អត់ ស្បែកជើងមិនបានទាំងអស់ទេ ។

ឈុនលី ៖ ចុះមីងមានទេ?

ស៊ីលឿត ៖ មាន ។

ឈុនលី ៖ ស្បែកយើងយ៉ាងម៉េច?

ស៊ីលឿត ៖ ស្បែកជើងកង់ឡានយើង គេឲ្យថានិរតីគេជិះអាចាស់ចេញគេយកអាថ្មីមក យើងពាក់កន្ត្រៃលគេ ។ សំពត់ក៏គេឲ្យ ជ្រលក់ឲ្យខ្មៅៗ ។

ឈុនលី ៖ ស្បៀកសំពត់ទេ មិនមែនខោទេ?

ស៊ីលឿត ៖ ខោផង ដូនកាលស្បៀកខោ ។ បើយើងនៅកន្លែងអីចឹងស្បៀកសំពត់ ។ ខោសអាវសក៏យើងយកទៅជ្រលក់ភក់ឲ្យខ្មៅ ។

ឈុនលី ៖ ជ្រលក់ភក់!

ស៊ីលឿត ៖ ដែរ!ស្នួល សំបកស្នួលយកវាទៅដាក់ទឹកទៅលាយភក់ទៀតឲ្យវាខ្មៅ ។

ឈុនលី ៖ ធ្វើខ្លួនឯងទៅ?

ស៊ីលឿត ៖ ចាស តែគេបើកខោអាវឲ្យគ្រប់គ្នា ។

ឈុនលី ៖ ចុះកាលលើកមុនវត្តព្រះនេត្រព្រះហ្នឹងគេធ្វើអី?

ស៊ីលឿត ៖ វត្តព្រះនេត្រព្រះគេធ្វើមន្ទីរពេទ្យ ។

ឈុនលី ៖ ចុះលោកអីមិនចេញអស់ហើយ ចេញតាំងពីពេលណា?

ស៊ីលឿត ៖ ចេញតាំងពី៧៥ ពេលខ្មែរក្រហមចូលមកលោកមិនដឹងទៅណាអស់ សឹកខ្លះអីខ្លះនោះឯងដាក់កន្លែងមន្ទីរពេទ្យ គ្រូនរង៉ារ ឈឺ រាគអាចម៍ រាគមូល ។

ឈុនលី ៖ ចុះរូបព្រះរូបអីហ្នឹងគេវ៉ៃចោលដែរអត់?

ស៊ីលឿត ៖ រូបព្រះក៏នៅមិនអីទេ គេវ៉ៃខ្លះហ្នឹងឯងរូបព្រះ ។ កាលនោះគេដែលជឿព្រះពុទ្ធសាសនាហ្អស!គេដាក់កប់ខ្មោចក្នុងនោះក៏មាន ។

ឈុនលី ៖ កប់ក្នុងវត្តហ្នឹង?

ស៊ីលឿត ៖ ចា៎!ខ្មោចដែលមួលឈាមគ្មានម្តាយគ្មានអីហ្នឹងចោលទៅ ។

ឈុនលី ៖ ដោយសារកន្ទែននោះពេទ្យ?

ស៊ីលឿត ៖ ចាំ!

ឈុនលី ៖ ចុះមីងដែលឈឺដែលអីទេទៅលើកទំនប់?

ស៊ីលឿត ៖ ខ្ញុំគ្រាន់តែថ្ងោះជើង គ្រិចកជើងសុំគេមកដេកពេទ្យ ។ កាលនោះថ្ងោះជើងលើកអីជិតភ្នំ លាបមកគេហៅអីណាទេ អូរលាប ។ ដល់លើកឡើងខ្ពស់ទៅវាថ្ងោះទៅដេកពេទ្យ ។ ពេទ្យគេបើកអាថ្នាំដូចយើងគេត្រាក្រហមៗ អាស្ពីរីនសៗឲ្យបីគ្រាប់ ។

ឈុនលី ៖ ហើយជាដែរអត់?

ស៊ីលឿត ៖ គ្រាន់តែបាត់គ្រុន ខ្ញុំបានតែប្រាំថ្ងៃខ្ញុំសុំទៅភូមិ ។

ឈុនលី ៖ ទៅភូមិធ្វើអីគេ?

ស៊ីលឿត ៖ ទៅសំរាកនៅភូមិបានប្រហែលម៉ោអាទិត្យគេដឹងថាខ្ញុំជាគេហៅទៅទៀតហើយ ថាមិនដែលបាននៅទេ ។

ឈុនលី ៖ មីងអត់ស្គាល់ទេអ្នកដែលនៅធ្វើការខុសត្រូវឲ្យយើងហ្នឹង?

ស៊ីលឿត ៖ ទេ ងាប់បាត់ហើយតាជាប់ ប្រធានភូមិ ។

ឈុនលី ៖ ជាប់ ឈ្មោះជាប់?

ស៊ីលឿត ៖ ចាំ!តាជាប់ គាត់ងាប់ហើយឥឡូវនេះនោះ ។ គាត់ប្រធានភូមិយើងនេះណាស់ ចាត់តាំងអ្នកណាអ្នកណី ទៅណាទៅណី តែគាត់ងាប់ហើយ ។

ឈុនលី ៖ ចុះអ្នកណាអ្នកដឹកនាំធំនៅទីនេះ?

ស៊ីលឿត ៖ ទេ ប្រធានភូមិគាត់ដឹកនាំ ប្រធានសហករណ៍ក៏យកទៅអស់ហើយ សុទ្ធតែអ្នកមកពីណោះហើយ ។

ឈុនលី ៖ ខាងណាវិញ?

ស៊ីលឿត ៖ ខាងនិរតី ។

ឈុនលី ៖ ចុះមុននិរតីក្រែងពួកពាយ័ព្យមកហ្អី?

ស៊ីលឿត ៖ ពួកពាយ័ព្យងាប់ដូចតែគ្នា តាជន ហើយនឹង តាក្រុក ។

ឈុនលី ៖ ស្លាប់ដោយសារអីគេ?

ស៊ីលឿត ៖ ទេ ពួកនោះពីដើមមិញ តាជន តាក្រុក ក្តាប់ ដល់ពួកនិរតីមកសំលាប់បន្តគ្នា ។ សំលាប់ពួកនោះម៉ោសារចេញទៅគេឡើងម្តង ។

ឈុនលី ៖ ហើយមីងភ័យទេ ឃើញគេសំលាប់គ្នាអីចឹង?

ស៊ីលឿត ៖ កាលនោះខ្ញុំ គេសំលាប់មិនឲ្យយើងដឹងទេ បាត់ខ្លួនៗ កាលនោះខ្ញុំមិនសូវនៅភូមិទៅ ច្រូតស្បូវច្រូតអីមិនសូវបាននៅភូមិទេ នៅម៉ាផ្ទាក់ម៉ាក្រៃគេដប់ថ្ងៃម៉ាអាទិត្យគេបញ្ជូនទៅទៀតទៅឲ្យតែនារីមិនបាននៅភូមិយូរទេទៅតែអីវ៉ាល ។

ឈុនលី ៖ ហើយដល់ពេលចេញពីត្រពាំងថ្មទៅមីងធ្វើការនៅឯណាទៀត?

ស៊ីលឿត ៖ ទំនប់រនុះបាញ់យើងនេះ ។

ឈុនលី ៖ ទំនប់រនុះបាញ់?

ស៊ីលឿត ៖ ចា៎! នៅខាងត្បូងនេះ ។

ឈុនលី ៖ នៅនេះជីកទំនប់ច្រើនណាស់មីង?

ស៊ីលឿត ៖ ទំនប់ច្រើន ទំនប់ហើយ ប្រឡាយអាប្រឡាយក្លោះយើងនេះតូចៗតាមស្រែនេះណាស ប្រពន្ធ័ស្រែម៉ាហិចតាៗក្រលាចក្រត្រង់ចេះណាសដប់មែត្រម្នាក់ៗ យើងលើកកៃកិបកុបៗទៅយើងហើយក៏បានសំរាកជីកក្តាមជីកអីទៅតាមស្រែយើងនេះណាសព្រោះអីការងារវាមិនសូវធ្ងន់ទេ ។ ដប់ម៉ែត្រមួយៗគ្រប់តែគ្នាទៅ ។ កាលនោះធិ ញ៉ូចអីហ្នឹងហើយដប់ម៉ែត្រមួយៗ យាយណាន យាយអីហ្នឹងស្គាល់ច្រើនណាស់ ប៉ុន្តែពួកនោះមិនដឹងជាក្មេចខ្ញុំអស់ហើយក៏មិនដឹងទេ ។ បាយជាមួយតែគ្នា មិនដែលមានអីហូបទេពួកនោះណាសពួកខ្ញុំចុះមានអត់អីណាដំឡូងអីដាំមុននោះជីកបានស្ងោរចែកគ្នាហូបទៅ អំពៅចោះអីចោះ ។ ពួកនោះមកដាំអីកើតគ្នាទើបតែមកមិនដែលចេះស្ទូងស្រូវទេ ញ៉ូច ធិ ហ្នឹងមានចេះច្រូតស្រូវឯណា...

ឈុនលី ៖ ហើយយើងបង្រៀនទៅ?

ស៊ីលឿត ៖ ហ្នឹងហើយ បង្រៀនឲ្យចេះទៅ មិនដែលចេះទេចេះតែបង្រៀនគ្នាទៅ ជួយច្រូតអីជួយយកមុខគ្នាទៅគ្នាមិនសូវចេះ ការចាប់តែដើមស្រូវមុនៗ បើដូចស្រុកយើងអីណេះចេះតែការសំណាមណាស ខាងនោះចាប់ដើមស្រូវមុន ធិ ញ៉ូច ។

ឈុនលី ៖ ចុះយើងច្រូតធម្មតាយើងកាន់...

ស៊ីលឿត ៖ យើងចូកស្រូវសិនបានយើងចាប់ ពួកនោះចាប់ដើមស្រូវមុនទេណាស ។

ឈុនលី ៖ ហើយគេថាឲ្យដែរពួកមេកង?

ស៊ីលឿត ៖ គេថាមិត្តឯងច្រូតមើលផងណាស មើលគេច្រូតៗ គ្នានោះមើលហើយបើមិនដែលធ្លាប់នោះ មិនថាយើងមិនថាគេមិនដែលធ្លាប់ទេ ដូចខ្ញុំអីចេះតែធ្លាប់ហើយចេះតែទៅកើតហើយនាំមុខគ្នាទៅ គ្នាចេះតែខំតាមឯងទៅណាស ។ គ្នាមកអីចឹងខ្លាចគេស្តីគេវ៉ៃ ។

ឈុនលី ៖ ហើយរួចពីហ្នឹងទៅណាទៀតមីង?

ស៊ីលឿត ៖ ដល់រួចពីអាទំនប់នោះក៏មកភូមិក៏...

ឈុនលី ៖ ទំនប់ដែលទៅលើកហ្នឹងអត់ធំទេ?

ស៊ីលឿត ៖ ធំ!

ឈុនលី ៖ ទំនប់រន្ទះបាញ់ហ្នឹង?

ស៊ីលឿត ៖ ចា៎! ផុតពីទំនប់នោះមកគេឲ្យមកផ្ទះសំរាកដល់គេឲ្យយើងនៅដូចថាម្ចាស់អូរចេះទៅច្រូត ស្រូវច្រូតអីម្តងនៅតាមដាកង ។

ឈុនលី ៖ ចឹងទំនប់រន្ទះបាញ់ហ្នឹងធំជីកយូរទេ?

ស៊ីលឿត ៖ ទេគេជីកមុនផង ខ្ញុំជីកក្រោយគេទៀតណាសដូចទៅជួយគេចឹងណាស ។

ឈុនលី ៖ ប្រហែលរយៈពេលប៉ុន្មានទៅមីង?

ស៊ីលឿត ៖ ខ្ញុំទៅប្រហែលម៉ាខែ ។

ឈុនលី ៖ ចឹងដូចយើងទៅធ្វើការកន្លែងណាអីចឹងគេមានកន្លែងឲ្យយើងសំរាក?

ស៊ីលឿត ៖ មាន ។

ឈុនលី ៖ រោងបាយរោងអីនៅហ្នឹង?

ស៊ីលឿត ៖ រោងបាយក៏មាន ហើយយើងមានចុងភៅយើងទៅក៏យើងដេកទៅ ។ ដូចអាទំនប់នេះ យើងជីករួចម៉ោងប្រាំអីចឹងគេឲ្យយើងទៅរែកថ្មទៀតម្នាក់បីដើង ។

ឈុនលី ៖ ចៅប៉ុន្មានមីង?

ស៊ីលឿត ៖ ចៅមួយកូនមីបងទើបតែបានកូនមួយ ។

ឈុនលី ៖ កូនមីងមានប៉ុន្មាននាក់?

ស៊ីលឿត ៖ កូនបួននាក់ ។

ឈុនលី ៖ នៅអស់ហើយ?

ស៊ីលឿត ៖ នៅនៅព្រំដែនពីរនៅពីរអីនេះរៀន មើលក្មួយ ។ ម្តាយវាទុកនៅនេះតាំងពីម៉ាខួប ឪពុកមិនដែលឃើញកូនទេ កូនក៏មិនដែលឃើញម៉ែទេ ។

ឈុនលី ៖ នៅតាំងពីម៉ាខួប!

ស៊ីលឿត ៖ ម៉ាខួបតូច ទៅធ្វើកសាងទៅ ។

ឈុនលី ៖ ចុះមីងពេលមីងចេញពីទំនប់រន្ទះបាញ់មកភូមិវិញ?

ស៊ីលៀត ៖ មកភូមិបានប្រហែលកន្លះខែគេឲ្យទៅវាលច្រូតស្រូវ ដល់ច្រូតស្រូវបានប្រហែលមិនដល់កន្លះខែក៏ស្រុកយើងចូល ។ យើងចូលហ្នឹងនៅឯវាលនោះណាស ។

ឈុនលី ៖ អីចឹងចូលមក៧៨ ៧៩ ។

ស៊ីលៀត ៖ នោះឯង!ចូលមលក៏ពួចាស់ៗថាស្រុកយើងសន្តិភាពហើយ ហួស!ប្រជាជនថ្មីក៏មក មិនបានគិតអ្នកណាទេរៀងតែខ្លួន ។ ខ្ញុំមកពីវាលមកពីច្រូត ហើយប្រជាជនថ្មីមកពីច្រូតអីវាលក៏ដឹកឥវ៉ាន់ទៅស្រុកទៅស្រែមិនបានជួបគ្នាទេ មិនដឹងទៅខាងណាខាងណីទេ យើងក៏យើងគេក៏គេ ខ្លះក៏នៅទីនេះអត់ទៅស្រុកទៅស្រែ គាកែវ ។ ស្គាល់ច្រើនណាស់ តែមិនដឹងឆាប់អីរស់ នារីៗស្គាល់ច្រើន ។ សព្វថ្ងៃពិបាករកណាស់ កាលលើកមុនលក់ឆ្នោតលក់អីតែឥឡូវគេឈប់ឲ្យលក់ហើយ ប្ដីខ្ញុំពិការ ។

ឈុនលី ៖ ប្ដីមីងពិការ?

ស៊ីលៀត ៖ ចា៎!

ឈុនលី ៖ ចុះប្ដីមីងទៅណាហើយ?

ស៊ីលៀត ៖ ទៅបុណ្យគេអីលិច បុណ្យបងប្អូន ។

ឈុនលី ៖ ចុះគាត់ពិការយូរឬនៅ?

ស៊ីលៀត ៖ ពិការតាំងពីខ្ញុំបានកូនមួយ ។

ឈុនលី ៖ មីងការឆ្នាំណា?

ស៊ីលៀត ៖ ខ្ញុំការប្រហែលឆ្នាំ៨១ ឡើង៧៩បានប៉ុន្មានប្រហែល៨១ ៨២ការ ។

ឈុនលី ៖ ចុះមីងថាមកនៅភូមិហ្នឹងភូមិណា?

ស៊ីលៀត ៖ ភូមិចាស់ខ្ញុំនេះ ។

ឈុនលី ៖ មកនៅផ្ទះចាស់វិញ?

ស៊ីលៀត ៖ ចា៎!

ឈុនលី ៖ ចុះផ្ទះមីងគេអត់យកធ្វើអីទេ?

ស៊ីលៀត ៖ អានោះផ្ទះចាស់គេរើអស់ហើយត្រង់នេះដាំសុទ្ធតែស្ពៃ ហើយមន ដល់ពេលមកពីនោះវិញរើពីនោះមក ។

ឈុនលី ៖ ឯណាដែលធ្វើផ្ទះថ្មីហ្នឹង?

ស៊ីលៀត ៖ នេះហើយ ផ្ទះនេះហើយ ។

ឈុនលី ៖ តាំងពីជំនាន់នោះមក?

ស៊ីលឿត :	ចាស! បើមានៗ ទៅផ្ទះធំ បើខ្ញុំប្ដីពិការរកអីមិនបានចេះតែនៅទៅ ។ រកអីបានបើប្ដីពិការ ហើយកូននៅតូចៗ ។

ឈុនលី :	គាត់ត្រូវអីគេបានពិការអីចឹង?

ស៊ីលឿត :	ត្រូវមីន ធ្វើទាហ៊ាន ។

ឈុនលី :	ទៅណាទៅបានអីចឹង?

ស៊ីលឿត :	ចេញទៅវាល កាលនោះសុំច្បាប់គេសំរាកសុំច្បាប់គេមកផ្ទះបើខ្ញុំទើបកូនបានពីរខួប មកផ្ទះបានតែម៉ាអាទិត្យទៅវាលក៏ត្រូវមីនអាពតដាក់ ដាច់ជើងមួយចំហៀង ។

ឈុនលី :	ត្រឹមណាទៅ?

ស៊ីលឿត :	នេះត្រឹមកំភួនជើង ។ មិនដែលបានធ្វើអី រកអីនឹងគេទេលក់តែឆ្នោតម៉ាមុខឥឡូវគេលែងឲ្យលក់ទៀត ។

ឈុនលី :	ចុះធ្វើនំធ្វើអីមីង?

ស៊ីលឿត :	ធ្វើនំអីលក់បើពេញតែផ្សារអីចេះនោះ ធ្វើអីមិនកើតកូនក៏រៀនពីរនាក់ ។

ឈុនលី :	ធ្វើស្រែ?

ស៊ីលឿត :	អត់មានស្រែធ្វើទេ កាលម្ដាយនៅឈឺក៏លក់អស់ទៅ ។ ខ្ញុំ កូនតូចៗជំពាក់គេរាប់ម៉ឺនក៏លក់សងគេអស់ឲ្យតែរស់ប៉ុណ្ណេះឡើង ។

ឈុនលី :	ថ្នាក់ទីប៉ុន្មានហើយ?

ស៊ីលឿត :	ថ្នាក់ទី៨ អាមួយនោះថ្នាក់ទី៧ ។

ឈុនលី :	រៀនគួររៀនអីទៀតហ្អី?

ស៊ីលឿត :	អត់រៀនផង រៀនក៏មិនមានប្រាក់ឲ្យរៀនទេ វាទាទៅតែថៃតែនៅតូចពេកមិនទាន់ឲ្យទៅ ។

ឈុនលី :	តែទៅថៃខានបានរៀនហើយ!

ស៊ីលឿត :	វាធ្លាប់ទៅម្ដងដែរក៏មកវិញ ទៅថៃគេមិនឲ្យធ្វើការនៅតូចៗថាយើងប្រើកំលាំងកូនក្មេងគេមិនឲ្យធ្វើការក៏មកវិញ ។

ឈុនលី :	អីចឹងរាល់ថ្ងៃបានកូនផ្ញើរមក?

ស៊ីលឿត :	ចាស ម៉ាខែបានមួយពាន់ប្រាំបានម៉ាចាយ ចុះគ្នារកមិនទាន់បានខែនេះភ្លៀង ។

ឈុនលី :	កូនពីរនាក់?

ស៊ីលឿត ៖ បីនាក់កូនប្រុសៗ កូនឈឺកាលនោះអត់តិចណាស់ហ្អស គ្រូនឈានបន្តោងស៊ីរ៉ូមគ្រប់គ្នា ។ យ៉ាប់ណាស់អ្នកស្រែយើងមិនមានមុខការ បើមានមុខការទៅចេះតែបានហើយណាស ខ្ញុំរួចពីអាពតមកតែប៉ុណ្ណេះ ។

ឈុនលី ៖ មីងរួចពីអាពតមកឆ្នាំប៉ែតជាងបានការ?

ស៊ីលឿត ៖ ប្រហែល៨២ បានការ ។

ឈុនលី ៖ ចុះគ្រួសារមីងគាត់ធ្វើអីគេ?

ស៊ីលឿត ៖ ធ្វើទាហ៊ាន ។

ឈុនលី ៖ ធ្វើទាហ៊ានតាំងពីអាពតមកហ្អី?

ស៊ីលឿត ៖ ទេ កាលអាពតនៅកុមារប្រាំពីប្រាំបីដណ្ដប់ដល់យួនចូលបានខ្ញុំឆ្នាំ៨២ ។ បានកូនមួយបានពីរខួបក៏ត្រូវមីន ។

ឈុនលី ៖ អីចឹងគាត់ទើបតែចូលធ្វើទាហ៊ានដែរ ក្រោយអាពត?

ស៊ីលឿត ៖ ចូលធ្វើទាហ៊ានណាស កាលនោះគេរើសទាហ៊ាន ។

ឈុនលី ៖ ច្បាំងជាមួយអ្នកណាគេ?

ស៊ីលឿត ៖ កាលនោះរឹកនោះខ្មែរក្រហមនៅនោះចេញពីភូមិ ។

ឈុនលី ៖ ឆ្នាំណាដែលគាត់ចូលធ្វើទាហ៊ាន?

ស៊ីលឿត ៖ ឆ្នាំដែលបានខ្ញុំហើយហ្នឹងក៏គេរើស ដូចឆ្នាំ៨១ បានខ្ញុំ៨២ ។ ដែលបានហ្នឹងគាត់ធ្វើទាហ៊ានហើយ ការបានតែម៉ាអាទិត្យគេទៅនៅកំពង់ក្រសាំង ។

ឈុនលី ៖ កំពង់ក្រសាំង?

ស៊ីលឿត ៖ ចា៎ នៅអីក្រោម ឈរជើងអីក្រោម ចុះទាហ៊ានមិនដែលនៅភូមិទេ ម៉ាអាទិត្យមកម្ដងដល់កាលនោះមកក៏ទៅបង់ត្រីក៏ត្រូវមីនបណ្ដោយ ។

ឈុនលី ៖ ហើយឈប់ធ្វើទាហ៊ានទៅ?

ស៊ីលឿត ៖ ចា៎! គេឲ្យប្រាក់ខែស៊ីដែរតិចៗ ។

ឈុនលី ៖ បានប៉ុន្មានទៅម៉ាខែ?

ស៊ីលឿត ៖ បានពីររយហា ពីរម៉ឺនប្រាំពាន់ តែសព្វថ្ងៃផ្ទេរមកខាងសង្គមកិច្ចបានដប់ម៉ឺន ប៉ុន្តែកូនគាត់អស់ហើយ ។

ឈុនលី ៖ ពីរម៉ឺនប្រាំពាន់ចាយយ៉ាងម៉េចទៅ?

ស៊ីលឿត ៖ មុនដំបូងពីរម៉ឺនប្រាំពាន់ណាស់ កាលនោះកូននៅតូចៗទៅបើកដល់ស្វាយអីណោះ ។

ឈុនលី ៖ ចាយយ៉ាងម៉េចទៅគ្រាន់តែជិះទៅក៏អស់ដែរ ។

ស៊ីលឿត ៖ នោះឯងកាលនោះធាក់កង់ទៅណាស ប្ដីខ្ញុំដល់សព្វថ្ងៃគេផ្ទេរមកជប់យើង បើកនៅសង្គមកិច្ច ដប់ម៉ឺននៅកាត់កូនកាត់អីទៀត ។

ឈុនលី ៖ ចុះរាល់ថ្ងៃបានប្រាក់ខែហ្នឹងដែរ?

ស៊ីលឿត ៖ បាន ថ្ងៃទី១ ទី២អីបើកហើយ ជួនកាលទៅថ្ងៃទី៥ បើកទៅបានទិញអង្ករស៊ី ។ ដល់បានលុយសេដ្ឋកិច្ចទៅចេះតែចាយគ្រប់ហើយមិនអីចឹងទេចាយមិនគ្រប់ទេកូនរៀន ចាយរាល់ថ្ងៃ ថៃក៏រៀនព្រឹកក៏រៀន ។

ឈុនលី ៖ ចុះមីងខស្សានិយាយរឿងខ្មែរក្រហមឲ្យកូនស្ដាប់ទេ?

ស៊ីលឿត ៖ ខ្ញុំ គេចែកសៀវភៅនោះខវាមើលប្រាប់វា ប្ដីខ្ញុំប្រាប់ចេះមួយចុះមួយរឿងខ្មែរក្រហមធ្វើការអីណាអីណីសៀវភៅលេក យុ យកមកចែកឲ្យកូនចៅមើល ។ វាមិនសូវដែលជឿទេកូនក្មេងសព្វថ្ងៃនេះវាមិនជឿទេ ។

ឈុនលី ៖ ខ្ញុំដូចមានមួយទៀត!

ស៊ីលឿត ៖ ការពិតហ្នឹងហ្អី?

ឈុនលី ៖ ចាំ!

ស៊ីលឿត ៖ ហ្នឹងឯង ។

ឈុនលី ៖ ចុះពេលនិយាយប្រាប់ជឿដែរកូនចៅ?

ស៊ីលឿត ៖ បន្ទាញវា វាថាលើកទំនប់យ៉ាប់ដែរម៉ែ? ខ្ញុំថាដែលមិនយ៉ាប់ហ្អីកូន លើកទំនប់ លើកដីលើកអី ។

ឈុនលី ៖ ប្រាប់វាជឿដែរ?

ស៊ីលឿត ៖ ជឿ ។

ឈុនលី ៖ មីងដូចមីងជិនាន់ អាពត ស្លៀកពាក់តែខោអាវខ្មៅចឹងក្រោយមកមីងស្លៀកទៀតដែរ?

ស៊ីលឿត ៖ ទេ មិនស្លៀកទេ ដូចថារួចពីអាពតមកក៏យើងមានខោអាវអីចេះស្លៀកដែរដែលយើងសល់ពីសង្គមមកណាស ពួកអ្នកភ្នំពេញមកចឹងគេមានសល់គេឲ្យយើងទៅដូរជិឡូងដូរអីបានអាណុងស្លៀក ។ បានប្រហែលជាបួនប្រាំខែយើងទៅជិរុំបានយកមាសទៅដូរស្រូវដូរអី អាខោអាវនោះចោលអស់បន់ឲ្យតែចូលនឹងអាលចោលឲ្យអស់ខោអាវខ្មៅ ។

ឈុនលី ៖ ចុះតាំងពីចេញពីអាពតដែលស្លៀកខោអាវខ្មៅទៀតដែរ?

ស៊ីលឿត ៖ ទេ មិនដែលស្លៀកពាក់ទេ ។

ឈុនលី ៖ អ៊ីចឹង? អាវខ្មៅមានដែរអត់?

ស៊ីលឿត ៖ អាវខ្មៅអត់ដែលមានសោះ ។

ឈុនលី ៖ ម៉េចចឹង?

ស៊ីលឿត ៖ ខ្ញុំមិនស្រលាញ់ ។

ឈុនលី ៖ តាំងពីដើមមកឬយ៉ាងម៉េច?

ស៊ីលឿត ៖ តាំងពីដើម តាំងពីអាពតមកក៏ខ្ញុំមិនដែលប្រើអាវខ្មៅដឹង ។

ឈុនលី ៖ ចុះមុនអាពតមកស្លៀកពាក់ដែរខ្មៅ?

ស៊ីលឿត ៖ ទេ មុនអាពតស្លៀកតែខោអាវរៀនសំពត់ខៀវអាវស ។

ឈុនលី ៖ អ៊ីចឹងស្អប់ខ្មៅដោយសារអាពត?

ស៊ីលឿត ៖ មិនមែនស្អប់ដោយសារអាពតទេ តែខ្ញុំមិនចូលចិត្តស្លៀកពាក់ខ្មៅ ។

ឈុនលី ៖ ម៉េចចឹង មីងគិតថាម៉េចបានស្អប់ខ្មៅ?

ស៊ីលឿត ៖ ខ្ញុំ ថាចូលចិត្តពណ៌ខៀវ តាំងពីដើមខ្ញុំមិនចូលចិត្តរឿងខ្មៅទេ មិនស្រលាញ់ទេពណ៌ខ្មៅ ខៀវ សអីទៅ ។

ឈុនលី ៖ ចឹងមិនមែនស្អប់ដោយសារអាពតទេ?

ស៊ីលឿត ៖ ស្អប់ដោយសារអាពត ។

ឈុនលី ៖ ចុះដល់កូនក្រោយៗទៀតមីងទិញខោអាវខ្មៅឲ្យទេ?

ស៊ីលឿត ៖ ឪវាទិញខោខ្មៅ អាវសរៀន ។

ឈុនលី ៖ ចឹងខោអាវធម្មតាអត់មានពណ៌ខ្មៅទេ?

ស៊ីលឿត ៖ អត់មានទេ មានតែខោរៀន ខោខ្មៅ អាវស ។ ចុះមានតែខ្មៅ ខៀវ ។

ឈុនលី ៖ អ៊ីចឹងអត់មានប៉ះពាល់ដល់មីងថាស្អប់ដោយសារខ្មែរក្រហមអីទេ?

ស៊ីលឿត ៖ ទេ ចេះតែស្អប់ ទុកតែក្នុងចិត្តទៅណាសអារឿងកន្លងហួសទៅហើយមិនដឹងធ្វើម៉េច ។

ឈុនលី ៖ ដល់ពេលឥឡូវនេះមីងដែលដឹងរឿងគេកាត់ទោសខ្មែរក្រហមទេ?

ស៊ីលឿត ៖ ខ្ញុំមិនដែលបានទៅរៀនសូត្រអីទេ ។

ឈុនលី ៖ ចុះឮតាមវ៉ាត់យូទេ?

ស៊ីលឿត ៖ ឮហើយ ឮតាមវ៉ាត់យូ ។

ឈុនលី ៖ ចុះមីងដឹងអីខ្លះទៅ?

ស៊ីលឿត ៖ មិនដឹងអីទេមិនយកចិត្តទុកដាក់ទេ ជួនកាលទៅឮរឿងកាត់ទោសខ្មែរក្រហមខ្ញុំបិទគ្រីប ។

ឈុនលី ៖ ម៉េចចឹង?

ស៊ីលឿត ៖ ខ្ញុំមិនស្តាប់ ខ្ញុំខ្ជិលស្តាប់ ខ្ជិលស្តាប់ណាស់ វាធុញ ។ ឮតែគាត់ទោសខ្មែរក្រហមខ្ញុំខ្ជិលស្តាប់ណាស់ ។

ឈុនលី ៖ ចឹងមីងអត់ចូលចិត្តស្តាប់?

ស៊ីលឿត ៖ ខ្ញុំមិនស្តាប់ ប្តីខ្ញុំស្តាប់ ខ្ញុំមិនដែលស្តាប់ទេ ។

ឈុនលី ៖ ចឹងមីងអត់ខ្វល់ទេ គាត់ទោសអីគាត់ទៅ?

ស៊ីលឿត ៖ ទេនៅតែគាត់បើវ៉ៃវាចោលដូចកាលវាវ៉ៃយើងទៅកាត់ទុកៗ គាត់ធ្វើអីខ្ញុំថាចឹងណាស ។ គាត់វ៉ៃវាចោលដូចកាលវាវ៉ៃយើង ។

ឈុនលី ៖ តែវ៉ៃចោលខុលហើយ មានតែដាក់គុកកាត់ ច្បាប់យើងអត់មានសំលាប់ដងហ្នឹង ។

ស៊ីលឿត ៖ ច្បាប់យើងអត់មានសំលាប់ ច្បាប់វាសំលាប់យើងកាលនោះណាស ។

ឈុនលី ៖ ច្បាប់យើងអត់ដូចវាទេ ។ មីងមានអីចង់ថែមទៀតទេមីង ។

ស៊ីលឿត ៖ អត់មានអីទេ ។

ឈុនលី ៖ ចុះមីងមានលេខទូរស័ព្ទទេ?

ស៊ីលឿត ៖ អត់មានទូរស័ព្ទទេ ។

ឈុនលី ៖ ចឹងអត់មានអីទៀតទេមីង?

ស៊ីលឿត ៖ អត់មានទេ ។

ឈុនលី ៖ ចឹងអគុណហើយមីង ។

ស៊ីលឿត ៖ ចា៎!

«ចប់»